**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខុទ្ទកាល័យ នាយករដ្ឋមន្ត្រី**

**ក្រុមអ្នកនាំពាក្យ**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលជំនួបរវាងឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ម៉ារីយ៉ា ដែល ខាមែន ម៉ូរេណូ (Maria Del Carmen Moreno) ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣

នៅវិមានសន្តិភាព ព្រឹកថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២៣ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានទទួលជំនួបសម្តែងការគួរសម និងជម្រាបលារបស់ លោកជំទាវ ម៉ារីយ៉ា ដែល ខាមែន ម៉ូរេណូ (Maria Del Carmen Moreno) ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបញ្ចប់អាណត្តិបេសកកម្មការទូតនៅកម្ពុជា ។

នៅក្នុងជំនួបនេះ លោកជំទាវ ម៉ារីយ៉ា ដែល ខាមែន ម៉ូរេណូ (Maria Del Carmen Moreno) បានសម្តែងនូវការអបអរសាទរចំពោះ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិតដែលត្រូវបានជ្រើសតាំងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ។ លោកជំទាវក៏បានសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះជោគជ័យជាច្រើនកន្លងមករបស់កម្ពុជា ដូចជាការគ្រប់គ្រងវិបត្តិនៃជំងឺកូវីដ-១៩ ការដាក់ចេញនូវកម្មវិធីជំនួយសង្គមដ៏មានប្រសិទ្ធភាព និងការធ្វើជាប្រធានអាស៊ានឆ្នាំ ២០២២ ប្រកបដោយមោទនភាព ជាពិសេសការជំរុញឱ្យប្រទេសភូមាកាន់តែចូលរួមក្នុងកិច្ចសន្ទនា។ លោកជំទាវក៏បានបង្ហាញនូវជំហរដ៏មុតមាំរបស់សហភាពអឺរ៉ុប ក្នុងការបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធបន្ថែមទៀតជាមួយកម្ពុជា ជាពិសេស ជាមួយរាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ក្រោមការដឹកនាំផ្ទាល់របស់ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ។ ជាមួយគ្នានេះ ដោយភ្ជាប់ជាមួយនឹងការជម្រាបលា លោកជំទាវឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបបានគោរពជម្រាបជូនឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិតថា លោកជំទាវនឹងបន្តបេសកកម្មបន្ទាប់នៅប្រទេសស្រីលង្កា និងពាំនាំនូវកិច្ចដំណើរបង្រួបបង្រួមជាតិដ៏ជោគជ័យរបស់កម្ពុជាដើម្បីចែករំលែកនៅទីនោះ ។

ជាកិច្ចឆ្លើយតប ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត បានសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការអបអរសាទររបស់លោកជំទាវ ក៏ដូចជាកិច្ចសហប្រតិបត្តិការស្អិតរមួតកន្លងមករវាងកម្ពុជានិងសហភាពអឺរ៉ុប ។ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ក៏បានលើកឡើងអំពីនិរន្តរភាពនៃគោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ដែលបន្តចាប់តាំងពីការដាក់ចេញយុទ្ធសាស្ត្រត្រីកោណ និង យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល ហើយសម្រាប់អាណត្តិនេះ ឆ្ពោះទៅមុខរាជរដ្ឋាភិបាលនឹងផ្ដោតជាពិសេសបំផុតទៅលើការកសាងមូលធនមនុស្ស ការកែទម្រង់វិស័យសុខាភិបាលនៅថ្នាក់មូលដ្ឋាន និងការកែទម្រង់វិស័យរដ្ឋបាលសាធារណៈ ។

ជាចុងក្រោយ កម្ពុជា និងសហភាពអឺរ៉ុបបានប្ដេជ្ញាបន្តជំរុញ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងសហភាពអឺរ៉ុប ឱ្យកាន់ជិតស្និទ្ធ ក៏ដូចជាការពង្រីកទិសដៅកិច្ចសហប្រតិបត្តិការទៅលើវិស័យដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេស វិស័យបណ្ដុះបណ្ដាលជំនាញ វិស័យសុខាភិបាល និង វិស័យមុខងារសាធារណៈ ដែលជាកិច្ចការសំខាន់ៗ នៃការអភិវឌ្ឍប្រកបដោយចីរភាព ។ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ក៏បានស្នើឱ្យសហភាពអឺរ៉ុបបន្តពិចារណាគាំទ្រ និងផ្ដល់ហិរញ្ញប្បទានលើ "កម្មវិធីសូចនាករពហុឆ្នាំ២០២១-២០២៧" ដំណាក់កាលទី២ បន្ថែមទៀតដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងការនាំចេញរបស់កម្ពុជាឆ្ពោះទៅកាន់ទីផ្សារសហភាពអឺរ៉ុប ។

ជាទីបញ្ចប់ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត បានជូនពរលោកជំទាវទទួលបានជោគជ័យក្នុងបេសកកម្មរបស់លោកជំទាវបន្តទៀតនៅថ្ងៃអនាគត ៕

ថ្ងៃចន្ទ ១២កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣

ខុទ្ទកាល័យ